## ខ្លឹមសារ សង្ខេប សេចក្តីសម្រេច លើពាក្យសុំ ការចាត់សកម្មភាពបន្ទាន់ អនុលោម តាមវិធាន ៣៥

ពាក្យគន្លឹះ៖ ការផ្អាកនីតិវិធី, កម្រិតភស្តុតាងនៃការទទួលយកពាក្យស្នើសុំ។

១. វិធាន ៣៥៖ ១. *អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរ មានសមត្ថកិច្ច នូវជនណាម្នាក់ជ្រៀតជ្រែក ដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម៖ ក. ផ្សាយព័ត៌មានសម្ងាត់...គ. បំផ្លាញ...ឯកសារ..ឆ.ញុះញង់ ឬប៉ុនប៉ងប្រព្រឹត្តិអំពើណាមួយដូចមានចែងខាងលើ។ ២. នៅពេលដែលសហចៅក្រមស៊ើបអង្កេត... មានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់...អាច៖ ក. ចាត់ការជាមួយបញ្ហានេះជាបន្ទាន់។...*

២. បន្ទាប់ពីការលាលែង របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងអំឡុងស៊ើបអង្កេតសំណុំរឿង ០០៣ និង ០០៤ ព្រមទាំងពិនិត្យមើលខ្លឹមសារលិខិតរបស់ចៅក្រមនេះ លោក **នួន ជា** បានទាញការសន្និដ្ឋានថា ការស៊ើបអង្កេតក្នុងសំណុំរឿង ០០២ និងការវិនិច្ឆ័យ នឹងមិនមានយុត្តិធម៌ទេ ដូចនេះ ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង (សាលាដំបូង) ផ្អាកនីតិវិធី (Stay of Proceeding) (កថាខ័ណ្ឌទី ៤)។ ជាការឆ្លើយតប សហព្រះរាជអាជ្ញា បានអះអាងថា ការចោទប្រកាន់នេះ វាជាការស្មាន (Specula tion) ដោយសារមិនមានបង្ហាញជាក់លាក់នូវ ការបំពានសិទ្ធិណាមួយរបស់ជនត្រូវចោទ នៅក្នុងដំណើរការនីតិវិធីដែលកំពុងបន្តនៃសំណុំរឿង ០០២។ បន្ថែមពីលើនេះ វាជាញត្តិពាក់ព័ន្ធនឹងបញ្ហាដដែលៗ ដែលធ្លាប់ត្រូវបានបដិសេធរួចហើយ នៅក្នុងអំឡុងពេលវិនិច្ឆ័យសេចក្តី និង ឧទ្ធរណ៍។ ជាចុងក្រោយសហព្រះរាជអាជ្ញា បានសង្កត់ធ្ងន់ថា ដើម្បីបញ្ចប់នីតិវិធី វាទាមទារឲ្យមានកម្រិតភស្តុតាងខ្ពស់ ហើយដែលលោក **នួន ជា** ខកខានមិនបានបំពេញ (កថាទី ៥ និង ៧)។[1]

៣. ដើម្បីទទួលរឿងមកដោះស្រាយ សាលាដំបូង ត្រូវពិនិត្យមើលថា តើញត្តិថ្មីនេះ ផ្អែកតាមស្ថានភាពថ្មី (new circumstances) ឬទេ? ហើយកត់សំគាល់ថា វាជាប្រធានបទដដែល ដែលសាលាដំបូងក៏ដូចជា អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធរួចហើយ (កថាទី៨)។ ចំពោះសំណើសុំស្រដៀងនឹងជំហររបស់សហព្រះរាជអាជ្ញា សាលាដំបូង អះអាងនូវស្តង់ដារ[2] រួចអះអាងថា **នួន ជា** មិន

---

[1] Finally, the Co-Prosecutors contend that the NUON Chea Application fails to meet *the high threshold* required for the drastic remedy of termination of proceedings.

[2] The trial chamber has previously outlined the extremely high threshold established by the international jurisprudence that must be satisfied in order for a stay of proceedings to be granted (para. 9).

បានបង្ហាញនូវផលប៉ះពាល់ជាក់ស្តែង (any tangible impact of allegation) ដូចនេះ ដំណោះស្រាយ ដែលត្រូវបានស្នើសុំ (ការផ្អាកនីតិវិធី) មិនសមស្រប និង មិនជាជម្រើសតែមួយ ដែលត្រូវផ្តល់នោះទេ (កថាទី ៩)។

៤. ឆ្លៀតក្នុងពេលនេះ សាលាដំបូង បានអះអាងថា ការចោទប្រកាន់ភាពមិនឯករាជ្យរបស់ចៅក្រម ដោយផ្អែកលើសញ្ញាតិមួយមុខ មិនស្របនឹងក្រមសីលធម៌ អនុវត្តនៅ *អវតក* ទេ។ ជាលទ្ធផល ការចោទប្រកាន់ធ្ងន់ធ្ងរ និងគ្មានភស្តុតាង នៃភាពមិនសមស្រប ក្នុងលក្ខណៈរើសអើង អាចនាំឲ្យមាន ការដាក់ទណ្ឌកម្ម (លើមេធាវី) អនុលោមតាមវិធាន ៣៨ (កថា១៦)។ ផ្អែកលើមូលដ្ឋានទាំងនេះ សាលាដំបូង សម្រេចបដិសេធ ញត្តិស្នើសុំនេះ។

ECCC Trial Chamber, Case 002, Decision on Application for Immediate Action Pursuant to Rule 35, E189/3, 22 November 2012 (Public)